CPL FOOTBALL AWARD 2022

# CPLនឹងរៀបចំពិធីប្រគល់ពានរង្វាន់ខេមបូឌានព្រីមៀរលីគឆ្នាំ២០២២ឆាប់ៗខាងមុខនេះ




ក្រុមហ៊ុនខេមបូឌានព្រីមៀរលីគ ហៅកាត់ថាCPL បានចេញសេចក្តីប្រកាសស្តីពីកម្មវិធីប្រគល់ពានរង្វាន់ខេមបូឌានព្រី-មៀរលីគ( CPL Football Award ) ឆ្នាំ២០២២ ដែលគ្រោងនឹងរៀបចំឡើងនាថ្ងៃពុធ ទី០៧ ខែធ្នូ នៅផ្សារទំនើប អ៊ីអន-ម៉លសែនសុខ ចាប់ពីម៉ោង ១៦:០០នាទីល្ងាចតទៅ។

គោលបំណងសំខាន់នៃការបង្កើតកម្មវិធីប្រគល់ពានរង្វាន់ខេមបូឌានព្រីមៀរលីគឆ្នាំ២០២២នេះ ធ្វើឡើងដើម្បីផ្តល់គុណតម្លៃប្រជាប្រិយភាព និងការគោរពស្រឡាញ់ ចំពោះកីឡាករ គ្រូបង្វឹក ក្លិបបាល់ទាត់ មន្រ្តីដឹកនាំការប្រកួត និងម្ចាស់ឧបត្ថម្ភ ក៏ដូចជាការបំពាក់មេដាយ និងប្រគល់ជូននូវពានរង្វាន់ដល់មន្ត្រី និងកីឡាករដែលទទួលបានពានរង្វាន់ ឯកត្តជនផងដែរ។

តម្លៃនិងចំនួនសំបុត្រ យើងបានកំណត់ជាក់លាក់ និងដាក់លក់នាពេលឆាប់ៗខាងមុខនេះ ហើយតម្លៃក្នុង០១សំបុត្រ ១០ដុល្លា ស្មើនឹង៤០.០០០រៀល ដោយទទួលបានអាហារសម្រន់និងការទស្សនានូវផ្ទាំងទស្សនីយភាពដ៏អស្ចារ្យ។ ចំពោះតម្លៃសំបុត្រ អាចនិយាយថាមិនមែនសម្រាប់ការរៀបចំកម្មវិធីទាំងមូលទេ គឺជាការអោយតម្លៃកម្មវិធីនេះ

- ដើម្បីញ៉ាំងអោយកម្មវិធីកាន់តែមានភាពទាក់ទាញ
- ដើម្បីបង្កើននូវចំនួនពានរង្វាន់សម្រាប់កីឡាករ
- ដើម្បីបង្កើនប្រាក់រង្វាន់សម្រាប់កីឡាករដែលត្រូវទទួលបានពានរង្វាន់ជ័យលាភី
- មានឱកាសជួបជាមួយនឹងកីឡាករដែលខ្លួនគាំទ្រ ស្រឡាញ់ពេញចិត្ត
- អាចចូលរួមលេងហ្គេម និងមានឱកាសឈ្នះរង្វាន់

គួរដឹងដែរថា នេះជាលើកទី១ហើយ ដែលក្រុមហ៊ុនខេមបូឌានព្រីមៀរលីគហៅកាត់ថា CPL រៀបចំឲ្យមានកម្មវិធី CPL Football Award 2022 នេះឡើង៕

ដោយឡែកនៅព្រឹកថ្ងៃកម្មវិធី CPLក៏មានរៀបចំការប្រកួតហ្គេម ( eFootball )ជាប្រភេទ Mobile Game ដែលរៀបចំនៅពេលព្រឹកចាប់ពីចាប់ពីម៉ោង ១០:០០នាទីព្រឹក ដល់ម៉ោង ១៣:០០នាទីថ្ងៃរសៀល។ ជ័យលាភីជើងឯកនឹងទទួលបាន រង្វាន់នៅក្នុងពិធីប្រគល់ពានរង្វាន់ខេមបូឌានព្រីមៀរលីគឆ្នាំ២០២២។